# បញ្ជីឆែកមើលសុវត្ថិភាពនៃភ្លើងឆេះនៅរដូវត្រជាក់

Fact Sheet 13 – Community Risk Management. Revised 28/09/2004 - Khmer

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## ហេតុការណ៍

ឆ្នាំមុននេះ ផ្ទះចំនួន៨៣៣៩ខ្នងត្រូវបានពាក់ពិននឹងភ្លើងឆេះនៅរដ្ឋ NSW ដែលមានមនុស្សស្លាប់អស់យ៉ាងហោចណាស់ ២០ នាក់និងរបួសចំនួន ៥៧៣នាក់ទៀត ។ ភ្លើងឆេះប្រមាណ ១៣០០ ឬ ៣០ ភាគរយ, បានកើតឡើងក្នុងអម្លុងពេលខែត្រជាក់ ។

(ស្ថិតិត្រឹមត្រូវនាថ្ងៃទី ០៤/០៦/០៤)

## តើផ្ទះលោកអ្នកមានសុវត្ថិភាពនៃភ្លើងឆេះនៅរដូវត្រជាក់ឬទេ?

យើងផ្តល់នូវឱវាទចំពោះបញ្ជីឆែកមើលសុវត្ថិភាពដ៏សាមញ្ញនេះដើម្បីជួយរក្សាផ្ទះលោកអ្នកឲ្យមានសុវត្ថិភាពពីភ្លើងឆេះនៅរដូវត្រជាក់នេះ ។ សូមធ្វើឲ្យប្រាកដថា លោកអ្នកនិងអ្នកនៅក្នុងផ្ទះលោកអ្នកទាំងអស់ធ្វើតាមឱវាទសុវត្ថិភាពដូចតទៅនេះ ៖

- ☐ សំខាន់បំផុត, សូមឲ្យគេដាក់គ្រឿងឲ្យសញ្ញាពេលមានផ្សែង (smoke alarms) ដែលអាចប្រើបានមួយចំនួនតាមកន្លែងនានានៅក្នុងផ្ទះលោកអ្នក ហើយធ្វើឲ្យប្រាកដថាលោកអ្នកធ្វើតេស្តវាជារឿយ ។
- ☐ សូមធ្វើឲ្យប្រាកដថាលោកអ្នកនិងគ្រួសារលោកអ្នកដឹងផ្លូវសុវត្ថិភាពពីរចេញពីបន្ទប់និមួយៗនៅក្នុងផ្ទះលោកអ្នក ។
- ☐ សូមសរសេរផែនការគេចចេញពីផ្ទះ ក្រែងលោមានភ្លើងឆេះ ហើយហាត់តាមជារឿយៗ ។
- ☐ កុំទុកការដាំស្លដោយឥតមានអ្នកចាំមើលឲ្យសោះ ។
- ☐ ប្រសិនបើលោកអ្នកមានកន្លែងដុតកំដៅនៅក្នុងផ្ទះ សូមធ្វើឲ្យប្រាកដថាបំពង់ផ្សែងនោះស្អាត ។
- ☐ ប្រសិនបើលោកអ្នកមានកន្លែងដុតកំដៅ សូមដាក់សំណាញ់ការពារនៅខាងមុខនៅពេលប្រើវា ។
- ☐ សូមឆែកមើលភួយអគ្គិសនីក្រែងលោមានខូច ឬមានខ្សែរដាច់ដាចមុននឹងដាក់ទៅលើគ្រែ ។
- ☐ សូមទុកដាក់វាំងនួន, កំរាលតុ និងកំរាលពូកឲ្យឆ្ងាយពីគ្រឿងដុតកំដៅដែលអាចលើកចុះឡើងបាន ។
- ☐ ដាក់សំលៀកបំពាក់សើមយ៉ាងហោចណាស់ ១ ម៉ែត្រពីគ្រឿងដុតកំដៅឬ កន្លែងដុតភ្លើងកំដៅហើយនិងកុំដើរចោលឲ្យសោះ ។
- ☐ ប្រសិនបើលោកអ្នកប្រើម៉ាស៊ិនធ្វើឲ្យស្ងួត សូមធ្វើឲ្យប្រាកដថាលោកអ្នកសំអាតតម្រងកំទេចម្តងឬរាល់ពេលលោកអ្នកប្រើវា។
- ☐ សូមប្រើគ្រឿងអគ្គិសនីតែមួយនៅកន្លែងដោតខ្សែភ្លើងហើយបិទនៅពេលមិនប្រើវា ។
- ☐ ពន្លត់ទៀននិងអណ្តាតភ្លើងឯទៀតជានិច្ច មុននឹងចូលគេង ។
- ☐ សូមប្រយ័ត្នប្រយែងជានិច្ចនៅពេលដុតទៀន ឬ អណ្តាតភ្លើងឯទៀត ។
- ☐ សូមទុកដាក់ឈើគូសឬដែកកេះនៅកន្លែងសុវត្ថិភាពកុំឲ្យក្មេងអាចយកបាន ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៏រំលត់ភ្លើង ឬមជ្ឍមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

## ចំណុចសំខាន់ៗនៃសុវត្ថិភាពនៃភ្លើងឆេះនៅរដូវត្រជាក់

- ដើម្បីធ្វើតេស្តភួយអគ្គិសនី សូមដាក់វាឲ្យរាបស្មើនៅលើគ្រែ, រួចមកបើកវា ប្រាំនាទីមុននឹងដាក់វាលើគ្រែសំរាប់ប្រើដើម្បីបញ្ជាក់ថាវាមិនអីទេ ។
- សូមឲ្យជាងដែលមានជំនាញដាក់គ្រឿងដុតកំដៅដែលដាក់ជាប់ (fixed appliances) ។
- គ្រឿងដុតកំដៅដោយប្រេង, ឧស្ម័ន ឬឧស ប្រហែលជាត្រូវការការថែទាំប្រចាំឆ្នាំ ។
- សូមប្រើ (fuse) តាមកំរិតដែលគេឲ្យឱវាទហើយសូមដាក់កុងតាក់អគ្គិសនីសំរាប់សុវត្ថិភាពមួយ (elcectric safety switch) ។
- ប្រសិនបើធ្វើទៅបាន, សូមទុកនៅផ្ទះបាយនូវគ្រឿងរំលត់ភ្លើងមួយ (fire extinguisher) និងភួយរំលត់ភ្លើងមួយ (fire blanket) ជិតផ្លូវចេញ ។
- កុំទុកទៀនឆេះ ឬអណ្តាតភ្លើងឯទៀតដោយគ្មានអ្នកចាំមើលឲ្យសោះ ។

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ ០០០**